លេខ / N°: D360/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 04-Sep-2018, 15:07
CMS/CFO: Ly Bunloung

---

# ដីកាបង្គាប់ឲ្យកោសលុបដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

## ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨

---

**ផ្ញើជូន÷**

**សហព្រះរាជអាជ្ញា÷**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ឈ
Richard ROGERS
Göran SLUITER

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី÷**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ីន សូវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I- ប្រវត្តិនីតិវិធី

1. កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ មេធាវីការពារក្ដីរបស់ អោ អាន (មេធាវីការពារក្ដី) បានដាក់សំណើបន្ទាន់សុំការកោសលុប និងការចាត់វិធានការបណ្ដោះអាសន្ន (សំណើ) នៅចំពោះមុខអង្គបុរេជំនុំជម្រះ (អ.ប.ជ)[1]។ មេធាវីការពារក្ដីលើកឡើងថាសហចៅក្រមស៊ើបអង្កេត ត្រូវបំពេញតួនាទីរបស់ខ្លួន *(functus officio)* ក្នុងសំណុំរឿង ០០៤/២ ។ អាស្រ័យហេតុនេះ មានតែ អ.ប.ជ[2] ទេ ដែលមានកាតព្វកិច្ចដោះស្រាយលើសំណើនានារបស់ខ្លួន។
2. មេធាវីការពារក្ដីបានស្នើសុំឲ្យលុបអាសយដ្ឋានបច្ចុប្បន្នរបស់ អោ អាន ចេញពីដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[3] (ស.ច.ស.អ) ដោយលើកឡើងអំពីលទ្ធភាពដែលអាចមានការរុកគួនរំខានពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយនានា ឬផ្ដល់នូវផលអាក្រក់ជាងនេះទៀតផង[4]។
3. មេធាវីការពារក្ដីបានគូសបញ្ជាក់ផងដែរថា ស.ច.ស.អ បានផ្សព្វផ្សាយឈ្មោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលបានស្នើសុំវិធានការការពារ នៅក្នុងសំណុំរឿង ០០៤/១។[5]

## II- ការពិភាក្សា

4. អ.ប.ជ មិនទាន់បានទទួលបណ្ដឹងឧទ្ធរណ៍ណាមួយនៅឡើយ។ ដូច្នេះ ខ្លួនពុំមានយុត្តាធិការក្នុងការទទួលយកសំណើនេះមកពិចារណាបាននោះទេ។ ការណ៍ដែលសហចៅក្រមស៊ើបអង្កេតត្រូវបំពេញតួនាទីរបស់ខ្លួន *(functus officio)* ចំពោះការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/២ ពុំមានន័យថាខ្លួនត្រូវបានហាមឃាត់មិនឲ្យកែកំហុសសាមញ្ញជាក់ស្ដែង ឬក៏ធ្វើការកែតម្រូវចាំបាច់លើកំហុសជាក់ស្ដែងផ្សេងៗទៀតក្នុងអត្ថបទនោះឡើយ។
5. ការគូសបញ្ជាក់របស់មេធាវីការពារក្ដីអំពីការរំលោភលើវិធានការការពារ គឺជាការត្រឹមត្រូវ។ បន្ទាប់ពីបានពិនិត្យមើលដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/២ រួចមក ខ្ញុំសូមកត់សម្គាល់ថា

---

[1] សំណុំរឿង ០០៤/២ ឯកសារ D360/1 សំណើបន្ទាន់សុំការកោសលុប និងការចាត់វិធានការបណ្ដោះអាសន្ន ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៨

[2] ដូចខាងលើ នៅកថាខណ្ឌ ២

[3] ដូចខាងលើ នៅកថាខណ្ឌ ៣ ដល់ ៥ និង ១២

[4] ដូចខាងលើ នៅកថាខណ្ឌ ៤

[5] ដូចខាងលើ នៅកថាខណ្ឌ ៦

មានការសរសេរឈ្មោះសាក្សីពីររូបដែលទទួលបានវិធានការការពារនៅក្នុងសំណុំរឿង 00៤/១។ កំហុសនេះ បណ្តាលមកពីការធ្វេសប្រហែសដែលគួរឲ្យសោកស្តាយ នៅក្នុងដំណើរការតាក់តែងសេចក្តីព្រាងក្នុងសំណុំរឿង 00៤/២។

6. ដោយសារស្ថានភាពបន្ទាន់ ខ្ញុំកត់សម្គាល់ដោយឥស្សរៈចិត្ត (*proprio motu*) ថា បញ្ហានេះពិតជាមានមែន ហើយខ្ញុំនឹងបង្គាប់ឲ្យកោសលុបនាមត្រកូលសាក្សីទាំងនេះចេញពីជើងទំព័រ ៤៧៩ ៥៣៤ និង ៥៣៧ និងពីឧបសម្ព័ន្ធ III និងឲ្យដកសំណៅជាសាធារណៈបច្ចុប្បន្ននៃដីកាដំណោះស្រាយរបស់ខ្ញុំ និង ឧបសម្ព័ន្ធ III ចេញពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់តុលាការ និងឲ្យចាត់ ចំណាត់ប្រភេទឯកសារទាំងនេះទៅជាឯកសារសម្ងាត់វិញ និងបង្គាប់ឲ្យដាក់សំណៅដែលបានកោសលុបថ្មីជាសាធារណៈវិញ។ ស្របតាមវិធាន ២៩ (៥) និង ៣៥ (១) (ក) នៃវិធានផ្ទៃក្នុង រាល់ការទម្លាយអត្តសញ្ញាណសាក្សីទាំងនេះក្នុងវេទិកាណាមួយ អាចត្រូវបានតុលាការដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច។

7. ខ្ញុំកត់សម្គាល់ទឡ្ហីករណ៍របស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងការបញ្ជាក់អំពីអាសយដ្ឋានបច្ចុប្បន្នរបស់ អោ អាន។ បញ្ហានេះមិនតម្រូវឲ្យមានដំណោះស្រាយបន្ទាន់បង្ខំដូចបញ្ហាឈ្មោះសាក្សីនោះទេ ពីព្រោះវាមានផលវិបាកច្រើន។ ដូច្នេះ យកល្អ ត្រូវស្តាប់អំណះអំណាងរបស់ភាគីនានាជាមុនសិន។ ទោះជាយ៉ាងនេះក្តី ខ្ញុំសូមកត់សម្គាល់ថា អោ អាន បានផ្តល់កិច្ចសម្ភាសដល់សារព័ត៌មានដោយស្ម័គ្រចិត្ត ក្នុងពេលកន្លងមក។

8. ខ្ញុំស្នើសុំឲ្យមេធាវីការពារក្តីពិចារណាដាក់សំណើរបស់ខ្លួនឡើងវិញជាបន្ទាន់ពាក់ព័ន្ធនឹងអាសយដ្ឋានរបស់ អោ អាន ជូនចំពោះសហចៅក្រមស៊ើបអង្កេត ទម្រាំដល់ពេលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូន អ.ប.ជ។

**យោងតាមហេតុផលដែលបានបញ្ជាក់ជូនខាងលើ ខ្ញុំ**

9. **បង្គាប់**ឲ្យក្រឡាបញ្ជី

ក) [redacted]

ខ) ចាត់ចំណាត់ប្រភេទលើសំណៅសាធារណៈបច្ចុប្បន្ននៃដីកាដំណោះស្រាយរបស់ខ្ញុំ និង ឧបសម្ព័ន្ធ III មកជាឯកសារសម្ងាត់វិញ។

គ) ដាក់សំណៅកោសលុបជាសាធារណៈតាមការបង្គាប់នៅត្រង់ចំណុច ក) ខាងលើ និង

10. **បង្គាប់ឲ្យ** ការិយាល័យកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញដកសំណៅបច្ចុប្បន្ននៃដីកាដំណោះស្រាយរបស់ខ្ញុំ និងឧបសម្ព័ន្ធ III ចេញពីគេហទំព័ររបស់តុលាការ និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត **ជាបន្ទាន់** និងដាក់ជំនួសវិញនូវសំណៅកោសលុបដូចមានបង្គាប់នៅកថាខណ្ឌ ៩ ខាងលើ។

សេចក្តីសម្រេចនេះដាក់ជូនជាភាសាអង់គ្លេសសិន ហើយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ។

ភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**